# English for Study in Australia
## កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី
### LESSON 25– Cheers!
### មេរៀនទី២៥ ៖ អំណរសាទរ

**STUDY NOTES**

**<u>តួអង្គ</u>**

Rocky:
រ៉ុកឃី ៖ និស្សិតអន្តរជាតិ
Angel:
អែនជល ៖ និស្សិតអន្តរជាតិ
Katie :
ខេតធី ៖ និស្សិតអន្តរជាតិ
Marion:
មារៀន ៖ គ្រូបង្រៀន
Waitress:
អ្នកបម្រើស្ត្រី ៖ នៅហាងភីហ្សា

**<u>សាច់រឿង</u>**

អែនជល ខេតធី និងរ៉ុកឃី ចូលហាងភីហ្សាដើម្បីទទួលទានអាហារពេលល្ងាច ជាមួយមិត្តភក្តិ និងគ្រូបង្រៀនរបស់ពួកគេ។

**<u>ព័ត៌មាន-វាក្យសព្ទសម្រាប់ប្រើនៅក្នុងភោជនីយដ្ឋាន និងសុជីវធម៌</u>**

| | |
|---|---|
| Waiting staff: waiter and waitress | Waiter (male) and waitress (female) អ្នកបម្រើ (ប្រុស) និងអ្នកបម្រើ (ស្រី)។ គួរផ្តល់ការគោរពដល់អ្នកទទួលភ្ញៀវ/អ្នកបម្រើ។ |
| Entrée, main course, dessert course | អាហារដំបូងឬអាហារក្លែម, អាហារចម្បង, បង្អែម។ អាហារទាំង៣មុខនេះ ចេញតាមលំដាប់ពីមុខមួយទៅមុខមួយទៀត។ នៅប្រទេសអូស្ត្រាលី អាហារដំបូង ឬក្លែម ចេញមុនអាហារ ចម្បង។ ជាទូទៅ អាហារដំបូងគឺជាអាហារតិចៗសម្រាប់កំដរមាត់ ដូចជាស៊ុប ឬគ្រឿងជ្រលក់(dip)។<br>ជាធម្មតា មនុស្សចូលចិត្តទទួលទានកាហ្វេ ក្នុងពេល |


© RadioAustralia/AMES 2008

| | |
|---|---|
| | បរិភោគបង្អែម។<br><br>មុខបង្អែមសម្រាប់អាហារ ដែលមានលក្ខណៈផ្លូវការ អាចជាបង្អែមលាយប៊ីរឬហ្វ្រូម៉ាស និងផ្លែឈើ។ |
| The bill | នៅក្នុងហាងកាហ្វេ និងភោជនីយដ្ឋានមួយចំនួន លោកអ្នកត្រូវបង់ប្រាក់មុន មុននឹងមានការផ្តល់អាហារជូន។ ប៉ុន្តែនៅក្នុងភោជនីយដ្ឋានភាគច្រើន គឺគិតលុយនៅពេលញ៉ាំអាហាររួចរាល់ ឬនៅពេលដែលលោកអ្នកហៅគេឱ្យគិតលុយ។ ប្រសិនបើលោកអ្នកទទួលបានវិក្កយបត្រ ក្នុងពេលជំណាលគ្នានឹងអាហារ លោកអ្នកមិនចាំបាច់គិតភ្លាមនោះទេ។ លោកអ្នកអាចរង់ចាំដល់ពេលដែលលោកអ្នករៀបចេញពីហាងក៏បានដែរ។ |
| To split the bill | ការបង់លុយឲ្យអ្នកគិតលុយតែចំណែកដែលលោកអ្នកទទួលទាន នៅពេលលោកអ្នកបរិភោគអាហារជាក្រុម ហើយវិធីនេះ មិនសូវអនុវត្តនៅប្រទេសអូស្ត្រាលីឡើយ។ ហាងភាគច្រើនមិនលើកទឹកចិត្តឱ្យធ្វើបែបនេះទេ។ អ្នកគិតលុយចង់ឱ្យអ្នកទទួលទានអាហារ គិតគូរលុយកាក់នៅក្នុងក្រុមឱ្យបានរួចរាល់ ហើយបង់លុយសរុបឲ្យហាងតែម្តង។ |
| To tip | ការឱ្យថ្លៃទឹកតែ។ នៅប្រទេសអូស្ត្រាលី ការឱ្យលុយធីបទៅឱ្យអ្នកទទួលភ្ញៀវឬអ្នកបម្រើ គឺមិនមែនជារឿងចាំបាច់នោះទេ។ |
| "Doggy bag" | សុំ "ច្រកអាហារនៅសល់ក្នុងថង់" គឺស្នើសុំឲ្យដាក់អាហារនៅសេសសល់ពីការបរិភោគរបស់លោកអ្នក ប្រសិនបើអាហារនោះនៅសល់ច្រើន ទៅក្នុងប្រអប់ដើម្បីយកទៅផ្ទះ។<br><br>ដោយខ្លាចប៉ះពាល់ដល់សុខភាព និងសុវត្ថិភាព ភោជនីយដ្ឋានមួយចំនួន នឹងមិនច្រកអាហារនៅសល់ក្នុងថង់ឲ្យលោកអ្នកយកទៅផ្ទះនោះទេ។ ប៉ុន្តែ សម្រាប់ |


© RadioAustralia/AMES 2008

| | |
|---|---|
| | អ្នកទទួលទានអាហារមួយចំនួន ដែលមានថវិកាតិចតួច អាហារនៅសល់ អាចជាអាហារមួយពេលទៀតនៅផ្ទះសម្រាប់ពួកគេ។ ប្រសិនបើលោកអ្នកយល់ឃើញដូចនេះ សូមលោកអ្នកយកប្រអប់ ឬស្បោងផ្ទាល់ខ្លួនមកភោជនីយដ្ឋានតែម្តងក៏បាន។ |

## <u>ភាសា-សំនួនវោហារ និងឃ្លាប្រយោគដែលមានន័យមិនធម្មតា</u>

| | |
|---|---|
| "I'll be in that" | ខ្ញុំចង់ធ្វើអញ្ចឹងដែរ។ |
| "Listen up!" | ឥឡូវនេះ ស្តាប់ខ្ញុំ។ |
| "I give up!" | (អស់សំណើច) ខ្ញុំមិនអាចស្វែរកហេតុផលជាមួយអ្នកទេ! ខ្ញុំមិនយល់ពីអ្នកទេ។ ខ្ញុំមិននិយាយជាមួយអ្នកអំពីរឿងនេះទៀតទេ។ |
| "Cheers!" | ស្រដៀងគ្នាទៅនឹងពាក្យ "សំណាងល្អ"។ ពាក្យនេះនិយាយនៅពេលបញ្ចប់ការនិយាយទូរស័ព្ទ ឬនៅពេលទង្គិចកែវនៅពេលជួបជុំគ្នាសាទរ។ |
| To "shout" | ប្រសិនបើមាននរណាម្នាក់ ផ្តល់ "shout" ឲ្យអ្នក មានន័យថា គេនឹងប៉ាវឬចេញថ្លៃចំណាយឱ្យអ្នក។ |
| To cover the cost | ចេញថ្លៃអាហារ ឬសេវាទាំងមូល។ |


© RadioAustralia/AMES 2008

## លំហាត់

### ១. វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| enjoyable | gift | interesting |
| lemonade | medium | (to) order |
| pizza | salad | spaghetti |
| thoughtful | topping | (to) treasure (something) |

### ២. ការហាត់រៀនភាសា លំហាត់គំរូ តេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word (or phrase) that best completes each sentence.
ចូរជ្រើសពាក្យដែលសមស្របបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះនៃអត្ថបទក្នុងប្រអប់ខាងក្រោម។

Cross one box for each number, eg: ☒
សូមគូសខ្វែងនៅក្នុងប្រអប់មួយសម្រាប់លេខនីមួយៗ ឧទាហរណ៍ ☒

1. Excuse me, we'd like _______________ now.

   ☐ to order ☐ order ☐ to take order ☐ to order you

2. What dish do you _______________?

   ☐ recommend ☐ say good ☐ recommending ☐ recommend me

3. This sauce is delicious, __________ spicy!

   ☐ too ☐ very ☐ mostly ☐ excellent

4. You're my guests so it's my ______________. I'll pay for you.


© RadioAustralia/AMES 2008

☐ shout ☐ yell ☐ pay ☐ give

5. If we all put in $8 that will __________ the bill.

☐ do ☐ finish ☐ share ☐ cover

## ៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

***សូរសំឡេង /f/ និង /p*** *៖ សូមហាត់និយាយដោយត្រូវប្រឹងពត់អណ្តាតរួចបញ្ចេញសំឡេងឲ្យបាន ព្ទៗ ៖*

**“Fifteen people paid five-fifty for pizza.”**

## ៤. អាសយដ្ឋានអ៊ីនធើរណិតដែលមានប្រយោជន៍

| | |
|---|---|
| **ព័ត៌មាន ៖** ប្រភេទនៃភីហ្សា | http://italianfood.about.com/library/weekly/aa021305.htm |
| ការពណ៌នាដ៏គួរឱ្យចង់សើចនៅប្រទេសអូស្រ្តាលី | http://www.bbc.co.uk/dna/h2g2/alabaster/A53650 |

ចម្លើយលំហាត់ទី 2: 1) to order 2) recommend 3) very 4) shout 5) cover

ABC Radio Australia


© RadioAustralia/AMES 2008